**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២២៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ០៥.នស.៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩២៥/០៣០ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–**

អនុក្រឹត្យនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ និងនីតិវិធីនៃការប្ដឹងតវ៉ា ការសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសដោយសញ្ជាតូបនីយកម្ម ការសុំលះបង់សញ្ជាតិខ្មែរដោយស្ម័គ្រចិត្ត និងការដកសញ្ជាតិខ្មែរ ព្រមទាំងចំនួនទឹកប្រាក់វិនិយោគ វិស័យអាទិភាព ប្រភេទគម្រោងវិនិយោគនិងលក្ខខណ្ឌផ្សេងទៀត និងចំនួនទឹកប្រាក់អំណោយជាសាច់ប្រាក់ដល់ថវិកាជាតិឬវិស័យមនុស្សធម៌របស់ជនបរទេសដែលស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងការបង្កើតនិងដំណើរការនៃគណៈកម្មការជាតិផ្ដល់យោបល់លើការដកសញ្ជាតិខ្មែរពីកំណើត ដើម្បីធានាការអនុវត្តច្បាប់ស្ដីពីសញ្ជាតិ ប្រកបដោយប្រសិទ្ធភាព។

**មាត្រា២ .–**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនបរទេសដែលមានបំណងទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ និងសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងពលរដ្ឋខ្មែរដែលត្រូវបាត់សញ្ជាតិខ្មែរតាមរយៈការលះបង់សញ្ជាតិខ្មែរដោយស្ម័គ្រចិត្ត និងការដកសញ្ជាតិខ្មែរ។

# ជំពូកទី២
# បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ព្រមទាំងនីតិវិធីនៃការប្ដឹងតវ៉ា
## ផ្នែកទី១
## បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ

**មាត្រា៣ .–**

ជនបរទេសដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ អាចទាមទារសញ្ជាតិខ្មែរបានដោយត្រូវដាក់ពាក្យសុំនិងបំពេញបែបបទ នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

**មាត្រា៤ .–**

ជនបរទេសដែលទាមទារសញ្ជាតិខ្មែរ ត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដាក់ពាក្យសុំ និងត្រូវបំពេញបែបបទ ដូចខាងក្រោម៖

១- ពាក្យទាមទារសញ្ជាតិខ្មែរ ចំនួន២(ពីរ)ច្បាប់។

២- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.។

៣- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា ទំហំ៤ស.ម.គុណ៦ស.ម ចំនួន១០(ដប់)សន្លឹក។

៤- សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

៥- លិខិតបញ្ជាក់ទីលំនៅ ចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

៦- ឯកសារបញ្ជាក់ការស្នាក់នៅរយៈពេល១២(ដប់ពីរ)ខែពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួន២(ពីរ)ច្បាប់។

៧- ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់សាមីខ្លួន ដែលនៅមានសុពលភាព ចំនួន២(ពីរ)ច្បាប់។

៨- ច្បាប់ថតចម្លងទិដ្ឋាការចូលនិងការបន្តរយៈពេលស្នាក់នៅបណ្ដោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានទាំងអស់របស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។
៩- លិខិតបញ្ជាក់កិរិយាមារយាទនិងសីលធម៌ ចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។
១០- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ចំនួន១(មួយ)ច្បាប់។
១១- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ចំនួន១(មួយ)ច្បាប់។
១២- លិខិតបញ្ជាក់សុខភាព ចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន២(ពីរ)ច្បាប់។

**មាត្រា៥ .-**

ជនបរទេសជាឪពុកឬម្ដាយ ដែលមានកូនរបស់ខ្លួនជាអនីតិជន មុនមានចំណងអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ អាចសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារបាន។ ក្នុងករណីនេះ ឪពុកឬម្ដាយត្រូវបំពេញបែបបទបន្ថែមសម្រាប់កូន ដូចខាងក្រោម៖

១- ពាក្យទាមទារសញ្ជាតិខ្មែរ ចំនួន២(ពីរ)ច្បាប់។
២- ជីវប្រវត្តិសង្ខេបរបស់កូន ចំនួន២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.។
៣- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា ទំហំ៤ស.ម.គុណ៦ស.ម. ចំនួន១០(ដប់)សន្លឹក។
៤- សេចក្ដីចម្លងសំបុត្រកំណើតរបស់កូន ចំនួន២(ពីរ)ច្បាប់។
៥- ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់កូនដែលនៅមានសុពលភាព ចំនួន២(ពីរ)ច្បាប់។
៦- ច្បាប់ថតចម្លងទិដ្ឋាការចូលនិងការបន្តរយៈពេលស្នាក់នៅបណ្ដោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានទាំងអស់របស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។
៧- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់កូន ចំនួន១(មួយ)ច្បាប់ ប្រសិនបើកូននោះមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។
៨- លិខិតបញ្ជាក់សុខភាពរបស់កូន ចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន២(ពីរ)ច្បាប់។

**មាត្រា៦ .-**

ជនបរទេសដែលទទួលបានសញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរជូនកូនរបស់ខ្លួនដែលជាអនីតិជនបាន ក្នុងករណីបុគ្គលនោះមិនបានស្នើសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារក្នុងដំណាក់កាលដំបូងនៃដំណើរការស្នើសុំទាមទារសញ្ជាតិខ្មែរ។ ក្នុងករណីនេះ ឪពុកឬម្ដាយដែលមានកូនជាអនីតិជន អាចបំពេញបែបបទស្នើសុំទាមទារសញ្ជាតិខ្មែរជំនួសកូនបាន ដូចខាងក្រោម៖

១- បែបបទនានា ដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះ។

២- លិខិតជានាអះអាងពីឪពុកឬម្តាយ ចំនួន២(ពីរ)ច្បាប់។

៣- លិខិតវេជ្ជសាស្ត្របញ្ជាក់ឌីអេនអេ(DNA) ក្នុងករណីចាំបាច់។

៤- ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែររបស់ឪពុកឬម្តាយ និងឯកសារបញ្ជាក់អត្តសញ្ញាណជាពលរដ្ឋខ្មែរ។

**មាត្រា៧ .-**

រាល់ឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ជនបរទេស ត្រូវមានការផ្តល់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមីខ្លួននោះ។

**មាត្រា៨ .-**

ទម្រង់និងនីតិវិធីនៃការទទួលនិងការពិនិត្យលើសំណុំបែបបទនៃការសុំទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៩ .-**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យ ស្រាវជ្រាវលើសំណុំបែបបទទាមទារសញ្ជាតិខ្មែរ ក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ស្តីពីសញ្ជាតិ និងបែបបទដែលមានចែងក្នុងមាត្រា៤ មាត្រា៥ និងមាត្រា៦នៃអនុក្រឹត្យនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំ ឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យនិងបន្តនីតិវិធីលើការទាមទារសញ្ជាតិខ្មែរ ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។

**មាត្រា១០ .-**

ការដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍របស់ជនបរទេស ត្រូវបង់កម្រៃសេវា។

កម្រៃសេវានៃការដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១១ .-**

ការផ្តល់សញ្ជាតិខ្មែរតាមករណីទាមទារសញ្ជាតិខ្មែរដល់ជនបរទេស ត្រូវសម្រេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១២ .-**

ជនដែលត្រូវបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់ជូនបន្ទាប់ពីបានបំពេញរួចរាល់នូវនីតិវិធីនៃការធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

បែបបទនិងនីតិវិធីនៃការធ្វើសម្បថ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី២
## នីតិវិធីនៃការប្តឹងតវ៉ា

**មាត្រា១៣ ._**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចសម្រេចបដិសេធចំពោះសំណើសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ក្នុងករណីណាមួយ ដូចខាងក្រោម៖

១- អាពាហ៍ពិពាហ៍ក្លែង។

២- ឯកសារក្លែងនៅក្នុងសំណុំបែបបទស្នើសុំទាមទារសញ្ជាតិខ្មែរ។

៣- អាពាហ៍ពិពាហ៍ផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៤- ការមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១១និងមាត្រា១២នៃច្បាប់ស្តីពីសញ្ជាតិ។

៥- ការមិនបានបំពេញកាតព្វកិច្ចដូចបានកំណត់ក្នុងមាត្រា៤ មាត្រា៥ និងមាត្រា៦នៃអនុក្រឹត្យនេះ។

**មាត្រា១៤ ._**

អ្នកស្នើសុំទាមទារសញ្ជាតិខ្មែរ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចប្តឹងតវ៉ាទៅតុលាការ ក្នុងអំឡុងពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសេចក្តីសម្រេចបដិសេធ។

**មាត្រា១៥ ._**

ទម្រង់និងនីតិវិធីនៃការប្តឹងតវ៉ាចំពោះការបដិសេធលើការសុំទាមទារសញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៣
## បែបបទនិងនីតិវិធីនៃការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម

**មាត្រា១៦ ._**

ជនបរទេសដែលមានបំណងសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវដាក់ពាក្យសុំនិងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

នៅពេលដាក់ពាក្យសុំ ជនបរទេសនេះត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៧ ._**

ជនបរទេសដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៩ មាត្រា២០ និងមាត្រា២១នៃច្បាប់ស្តីពីសញ្ជាតិ ត្រូវដាក់ពាក្យសុំនិងបំពេញបែបបទ ដូចខាងក្រោម៖

១- ពាក្យសុំចូលសញ្ជាតិខ្មែរ ចំនួន២(ពីរ)ច្បាប់។

២- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.។

៣- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា ទំហំ៤ស.ម.គុណ៦ស.ម. ចំនួន១០(ដប់)សន្លឹក។

៤- ច្បាប់ថតចម្លងបណ្ណស្នាក់នៅ ចេញដោយសមត្ថកិច្ចអន្តោប្រវេសន៍ ចំនួន២(ពីរ)ច្បាប់។

៥- បណ្ណការងារឬឯកសារបញ្ជាក់មុខរបរ ចំពោះជនបរទេសអន្តោប្រវេសន្តដែលបានកំណត់នៅក្នុងចំណុចទី៣ មាត្រា១៩ និងមាត្រា២០នៃច្បាប់ស្តីពីសញ្ជាតិ ចំនួន២(ពីរ)ច្បាប់ ឬឯកសារពាក់ព័ន្ធនឹង

ការវិនិយោគ ចំពោះជនបរទេសដែលបានកំណត់នៅក្នុងចំណុចទី៤ មាត្រា១៩ និងមាត្រា២១ នៃច្បាប់ស្តីពីសញ្ជាតិ ចំនួន២(ពីរ)ច្បាប់។

៦- លិខិតបញ្ជាក់ទីលំនៅ ចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

៧- សេចក្តីចម្លងសំបុត្រកំណើតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ចំនួន២(ពីរ)ច្បាប់។

៨- ឯកសារបញ្ជាក់ការស្នាក់នៅជាប់ឬពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា ដូចបានកំណត់ក្នុងមាត្រា១៩ មាត្រា២០ និងមាត្រា២១នៃច្បាប់ស្តីពីសញ្ជាតិ ចំនួន២(ពីរ)ច្បាប់។

៩- ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់សាមីខ្លួន ដែលនៅមានសុពលភាព ចំនួន២(ពីរ)ច្បាប់។

១០- ច្បាប់ថតចម្លងទិដ្ឋាការចូលនិងការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានទាំងអស់របស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

១១- លិខិតបញ្ជាក់កិរិយាមារយាទ ចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

១២- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ចំនួន១(មួយ)ច្បាប់។

១៣- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ចំនួន១(មួយ)ច្បាប់។

១៤- លិខិតបញ្ជាក់សុខភាព ចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន២(ពីរ)ច្បាប់។

**មាត្រា១៨ .-**

ជនបរទេសដែលធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិឬវិស័យមនុស្សធម៌ អាចសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងត្រូវបំពេញបែបបទ ដូចខាងក្រោមៈ

១- ពាក្យសុំចូលសញ្ជាតិខ្មែរ ចំនួន២(ពីរ)ច្បាប់។

២- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.។

៣- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា ទំហំ៤ស.ម.គុណ៦ស.ម. ចំនួន១០(ដប់)សន្លឹក។

៤- លិខិតបញ្ជាក់អំពីអំណោយជាសាច់ប្រាក់ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ចំនួន១(មួយ)ច្បាប់។

៥- សេចក្តីចម្លងសំបុត្រកំណើតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ចំនួន២(ពីរ)ច្បាប់។

៦- ឯកសារបញ្ជាក់ការស្នាក់នៅជាប់ឬពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជា ដូចបានកំណត់ក្នុងមាត្រា២២នៃច្បាប់ស្តីពីសញ្ជាតិ ចំនួន២(ពីរ)ច្បាប់។

៧- ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់សាមីខ្លួន ដែលនៅមានសុពលភាព ចំនួន២(ពីរ)ច្បាប់។

៨- ច្បាប់ថតចម្លងទិដ្ឋាការចូលនិងការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានទាំងអស់របស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

៩- លិខិតបញ្ជាក់កិរិយាមារយាទ ចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

១០- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ចំនួន១(មួយ)ច្បាប់។

១១- លិខិតបញ្ជាក់សុខភាព ចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន២(ពីរ)ច្បាប់។

**មាត្រា១៩ .-**

ជនបរទេសដែលមានគុណសម្បត្តិពិសេសឬថ្វីដៃពិសេស អាចសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងត្រូវបំពេញបែបបទ ដូចខាងក្រោម៖

១- ពាក្យសុំចូលសញ្ជាតិខ្មែរ ចំនួន២(ពីរ)ច្បាប់។

២- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.។

៣- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.ម.គុណ៦ស.ម. ចំនួន១០(ដប់)សន្លឹក។

៤- លិខិតទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជាអំពីគុណសម្បត្តិពិសេសឬថ្វីដៃពិសេស ចំនួន១(មួយ)ច្បាប់។

៥- សេចក្តីចម្លងសំបុត្រកំណើតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ចំនួន២(ពីរ)ច្បាប់។

៦- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ចំនួន១(មួយ)ច្បាប់។

៧- ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់សាមីខ្លួន ដែលនៅមានសុពលភាព ចំនួន២(ពីរ)ច្បាប់។

៨- ច្បាប់ថតចម្លងទិដ្ឋាការចូលនិងការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានទាំងអស់របស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

៩- លិខិតបញ្ជាក់សុខភាព ចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន២(ពីរ)ច្បាប់។

**មាត្រា២០ .-**

ជនបរទេសដែលមានសហព័ទ្ធ ដែលមានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ។ សហព័ទ្ធរបស់ជនបរទេសនោះ ត្រូវបំពេញបែបបទទៅតាមករណីនីមួយៗ ដូចខាងក្រោម៖

១- ចំពោះសហព័ទ្ធរបស់ជនបរទេសដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៩ មាត្រា២០ និងមាត្រា២១នៃច្បាប់ស្តីពីសញ្ជាតិ ត្រូវដាក់ពាក្យសុំនិងបំពេញបែបបទដូចបានកំណត់ក្នុងមាត្រា១៧នៃអនុក្រឹត្យនេះ លើកលែងតែចំណុចទី៥ ហើយត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចំនួន២(ពីរ)ច្បាប់។

២- ចំពោះសហព័ទ្ធរបស់ជនបរទេសដែលធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិឬវិស័យមនុស្សធម៌ ត្រូវបំពេញបែបបទដូចបានកំណត់ក្នុងមាត្រា១៨នៃអនុក្រឹត្យនេះ លើកលែងតែចំណុចទី៤ ហើយត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចំនួន២(ពីរ)ច្បាប់។

៣- ចំពោះសហព័ទ្ធរបស់ជនបរទេសដែលមានគុណសម្បត្តិពិសេសឬថ្វីដៃពិសេសត្រូវបំពេញបែបបទដូចបានកំណត់ក្នុងមាត្រា១៩នៃអនុក្រឹត្យនេះ លើកលែងតែចំណុចទី៤ ហើយត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចំនួន២(ពីរ)ច្បាប់។

**មាត្រា២១ .-**

ជនបរទេសដែលមានកូនជាអនីតិជន មានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ។ ក្នុងករណីនេះ ឪពុកឬម្ដាយត្រូវបំពេញបែបបទបន្ថែមសម្រាប់កូន ដូចខាងក្រោម៖

១- ពាក្យសុំចូលសញ្ជាតិខ្មែរ ចំនួន២(ពីរ)ច្បាប់។

២- ជីវប្រវត្តិសង្ខេបរបស់កូន ចំនួន២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.។

៣- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.ម.គុណ៦ស.ម. ចំនួន ១០(ដប់) សន្លឹក។

៤- សេចក្ដីចម្លងសំបុត្រកំណើតរបស់កូន ចំនួន២(ពីរ)ច្បាប់។

៥- ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់កូន ដែលនៅមានសុពលភាព ចំនួន២(ពីរ)ច្បាប់។

៦- ច្បាប់ថតចម្លងទិដ្ឋាការចូលនិងការបន្តរយៈពេលស្នាក់នៅបណ្ដោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានទាំងអស់របស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់។

៧- លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់កូន ចំនួន១(មួយ)ច្បាប់ ប្រសិនបើកូននោះមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។

៨- លិខិតថ្កោលទោសមានសុពលភាព ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ចំនួន១(មួយ)ច្បាប់ ប្រសិនបើកូននោះមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ ហើយបានចូលមករស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា។

៩- លិខិតបញ្ជាក់សុខភាពរបស់កូនចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន២(ពីរ)ច្បាប់។

**មាត្រា២២ .-**

ជនបរទេសដែលទទួលបានសញ្ជាតិខ្មែរតាមរយៈសញ្ជាតូបនីយកម្ម អាចស្នើសុំសញ្ជាតិខ្មែរជូនកូនរបស់ខ្លួនដែលជាអនីតិជនបាន ក្នុងករណីបុគ្គលនោះមិនបានស្នើសុំចូលសញ្ជាតិខ្មែរជាចង្កោមគ្រួសារ ក្នុងដំណាក់កាលដំបូងនៃដំណើរការស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម។ ក្នុងករណីនេះ ឪពុកឬម្ដាយដែលមានកូនជាអនីតិជនអាចបំពេញបែបបទស្នើសុំចូលសញ្ជាតិខ្មែរជំនួសកូនបាន ដូចខាងក្រោម៖

១- បែបបទនានា ដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ។

២- លិខិតធានាអះអាងពីឪពុកឬម្ដាយ ចំនួន២(ពីរ)ច្បាប់។

៣- លិខិតវេជ្ជសាស្ត្របញ្ជាក់ឌីអេនអេ(DNA) ក្នុងករណីចាំបាច់។

៤- ព្រះរាជក្រឹត្យផ្ដល់សញ្ជាតិខ្មែររបស់ឪពុកឬម្ដាយ និងឯកសារបញ្ជាក់អត្តសញ្ញាណជាពលរដ្ឋខ្មែរ។

**មាត្រា២៣ .-**

រាល់ឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ជនបរទេស ត្រូវមានការផ្ដល់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមីខ្លួននោះ។

**មាត្រា២៤ .-**

ទម្រង់និងនីតិវិធីនៃការទទួលនិងការពិនិត្យលើសំណុំបែបបទនៃការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា២៥ .-**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យស្រាវជ្រាវលើសំណុំបែបបទសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីដែលអ្នកស្នើសុំ មិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ស្ដីពីសញ្ជាតិ និងបែបបទដែលមានចែងក្នុងមាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំ ឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យនិងបន្តនីតិវិធីលើការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។

**មាត្រា២៦ .-**

ការដាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មរបស់ជនបរទេស ត្រូវបង់កម្រៃសេវា។

កម្រៃសេវានៃការដាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៧ .-**

ការផ្ដល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មដល់ជនបរទេស ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្ដីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា២៨ .-**

ជនដែលត្រូវបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ដល់ជូនបន្ទាប់ពីបានបំពេញរួចរាល់នូវនីតិវិធីនៃការធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

បែបបទនិងនីតិវិធីនៃការធ្វើសម្បថ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៤

## ចំនួនទឹកប្រាក់ វិស័យអាទិភាព និងប្រភេទគម្រោងវិនិយោគ ព្រមទាំងលក្ខខណ្ឌផ្សេងទៀត និងចំនួនទឹកប្រាក់អំណោយជាសាច់ប្រាក់ដល់ថវិកាជាតិឬវិស័យមនុស្សធម៌

### ផ្នែកទី១

### ចំនួនទឹកប្រាក់ វិស័យអាទិភាព និងប្រភេទគម្រោងវិនិយោគ ព្រមទាំងលក្ខខណ្ឌផ្សេងទៀត

**មាត្រា២៩ .-**

ជនបរទេសណាដែលបានទទួលការអនុញ្ញាតឱ្យវិនិយោគត្រឹមត្រូវតាមច្បាប់ពីស្ថាប័នមានសមត្ថកិច្ច ស្របតាមគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល អាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបានតាមមាត្រា២១នៃច្បាប់ស្ដីពីសញ្ជាតិ លុះត្រាតែជនបរទេសនោះបាន៖

១- ចំណាយទុនផ្ទាល់ខ្លួនអនុវត្តគម្រោងវិនិយោគជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពី ៤ ០០០ ០០០ ០០០(បួនប៊ីលាន)រៀលឡើងទៅ។

២- វិនិយោគស្ថិតនៅក្នុងវិស័យអាទិភាពដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

៣- អនុវត្តប្រភេទគម្រោងវិនិយោគដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

៤- បំពេញលក្ខខណ្ឌផ្សេងទៀត ដូចជាកាតព្វកិច្ចសារពើពន្ធ ផែនការវិនិយោគជាដើម។

**មាត្រា៣០ .-**

ទុនអនុវត្តគម្រោងវិនិយោគ វិស័យអាទិភាព ប្រភេទគម្រោងវិនិយោគ និងលក្ខខណ្ឌផ្សេងទៀត ក្នុងការវិនិយោគជាក់ស្តែង សម្រាប់ជនបរទេសជាអ្នកវិនិយោគដែលស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវពិនិត្យវាយតម្លៃដោយក្រសួងមហាផ្ទៃ។ ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងសម្រេច។

ទុនវិនិយោគផ្ទាល់ខ្លួន ត្រូវមានប្រភពច្បាស់លាស់និងស្របច្បាប់។

## ផ្នែកទី២

## ចំនួនទឹកប្រាក់អំណោយជាសាច់ប្រាក់ដល់ថវិកាជាតិឬវិស័យមនុស្សធម៌

**មាត្រា៣១ .-**

ជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ផ្ទាល់ខ្លួនដល់ថវិកាជាតិ សម្រាប់ជាផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឬវិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបានតាមមាត្រា២២នៃច្បាប់ស្តីពីសញ្ជាតិ ក្នុងករណីដែលជននោះបានធ្វើអំណោយជាសាច់ប្រាក់ចំនួនចាប់ពី១២ ០០០ ០០០ ០០០(ដប់ពីរប៊ីលាន)រៀលឡើងទៅ។

អំណោយជាសាច់ប្រាក់ផ្ទាល់ខ្លួន ត្រូវមានប្រភពច្បាស់លាស់និងស្របច្បាប់។

អំណោយនោះត្រូវបង់ចូលថវិកាជាតិ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## បែបបទនិងនីតិវិធីនៃការសុំលះបង់សញ្ជាតិខ្មែរ

**មាត្រា៣២ .-**

ប្រជាពលរដ្ឋខ្មែរដែលមានអាយុ១៨(ដប់ប្រាំបី)ឆ្នាំយ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបានដោយស្ម័គ្រចិត្ត ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀត។

ពលរដ្ឋខ្មែរដែលមានបំណងសុំលះបង់សញ្ជាតិខ្មែរ ត្រូវដាក់ពាក្យសុំនិងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។

**មាត្រា៣៣ .-**

ពលរដ្ឋខ្មែរដែលសុំលះបង់សញ្ជាតិខ្មែរ ត្រូវដាក់ពាក្យសុំលះបង់សញ្ជាតិខ្មែរនិងត្រូវបំពេញបែបបទដូចខាងក្រោម៖

១- ពាក្យសុំលះបង់សញ្ជាតិខ្មែរ ចំនួន២(ពីរ)ច្បាប់។

២- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន ចំនួន២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.។

៣- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.ម.គុណ៦ស.ម. ចំនួន១០(ដប់)សន្លឹក។

៤- លិខិតបញ្ជាក់សញ្ញាតិមួយផ្សេងទៀត ឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលសាមីខ្លួនបានដាក់ពាក្យសុំចូលសញ្ជាតិ ចំនួន១(មួយ)ច្បាប់។
៥- ច្បាប់ចម្លងសៀវភៅគ្រួសារឬសៀវភៅស្នាក់នៅ ចំនួន២(ពីរ)ច្បាប់។
៦- សេចក្តីចម្លងសំបុត្រកំណើតឬច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬច្បាប់ចម្លងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ចំនួន២(ពីរ)ច្បាប់។
៧- ចំពោះពលរដ្ឋខ្មែររស់នៅបរទេសស្របច្បាប់ ត្រូវមានលិខិតបញ្ជាក់ទីលំនៅរបស់សាមីខ្លួននៃប្រទេសនោះ ចំនួន១(មួយ)ច្បាប់។

**មាត្រា៣៤ ._**

ពលរដ្ឋខ្មែរដែលមានកូនជាអនីតិជន មានបំណងស្នើសុំលះបង់សញ្ជាតិខ្មែរ អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារបាន។ ក្នុងករណីនេះ ឪពុកឬម្តាយត្រូវបំពេញបែបបទបន្ថែមសម្រាប់កូន ដូចខាងក្រោម៖
១- ពាក្យសុំលះបង់សញ្ជាតិខ្មែរ ចំនួន២(ពីរ)ច្បាប់។
២- ជីវប្រវត្តិសង្ខេបរបស់កូន ចំនួន២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.។
៣- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.ម.គុណ៦ស.ម. ចំនួន១០(ដប់)សន្លឹក។
៤- លិខិតបញ្ជាក់សញ្ញាតិមួយផ្សេងទៀត ឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលសាមីខ្លួនបានដាក់ពាក្យសុំចូលសញ្ជាតិ ចំនួន១(មួយ)ច្បាប់។
៥- ច្បាប់ចម្លងសៀវភៅគ្រួសារឬសៀវភៅស្នាក់នៅ ចំនួន២(ពីរ)ច្បាប់។
៦- សេចក្តីចម្លងសំបុត្រកំណើតរបស់កូន ចំនួន២(ពីរ)ច្បាប់។
៧- ច្បាប់ចម្លងលិខិតឆ្លងដែនរបស់កូន ដែលនៅមានសុពលភាព ចំនួន២(ពីរ)ច្បាប់។

**មាត្រា៣៥ ._**

រាល់ឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ពលរដ្ឋខ្មែរកំពុងរស់នៅ ត្រូវមានការផ្តល់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមីខ្លួននោះ។

**មាត្រា៣៦ ._**

ទម្រង់និងនីតិវិធីនៃការទទួលនិងការពិនិត្យលើសំណុំបែបបទនៃការសុំលះបង់សញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៣៧ ._**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យស្រាវជ្រាវលើសំណុំបែបបទសុំលះបង់សញ្ជាតិខ្មែរក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីដែលអ្នកស្នើសុំ មិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ស្តីពីសញ្ជាតិ និងបែបបទដែលមានចែងក្នុងមាត្រា៣៣និងមាត្រា៣៤នៃអនុក្រឹត្យនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវពិនិត្យនិងបន្តនីតិវិធីលើការសុំលះបង់សញ្ជាតិខ្មែរ ក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។

**មាត្រា៣៨ .-**

ការដាក់ពាក្យសុំលះបង់សញ្ជាតិរបស់ពលរដ្ឋខ្មែរ ត្រូវបង់កម្រៃសេវា។

កម្រៃសេវានៃការដាក់ពាក្យសុំលះបង់សញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៩ .-**

ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរដល់ពលរដ្ឋខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៦
## ការដកសញ្ជាតិខ្មែរពីកំណើត
### ផ្នែកទី១
### លក្ខខណ្ឌនៃការដកសញ្ជាតិខ្មែរពីកំណើត

**មាត្រា៤០ .-**

អនុលោមតាមបញ្ញត្តិនៃមាត្រា២៩ថ្មីនៃច្បាប់ស្តីពីសញ្ជាតិ ការដកសញ្ជាតិខ្មែរពីកំណើតពីប្រជាពលរដ្ឋខ្មែរអាចធ្វើទៅបានក្នុងករណីណាមួយ ដូចខាងក្រោម៖

១- ប្រព្រឹត្តអំពើក្បត់ជាតិឬធ្វើសកម្មភាពឃុបឃិតគ្នាជាមួយបរទេស ដែលនាំឱ្យអន្តរាយដល់ផលប្រយោជន៍ស្នូលរបស់ព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើសកម្មភាពដែលនាំឱ្យអន្តរាយដល់អធិបតេយ្យជាតិ បូរណភាពទឹកដី និងសន្តិសុខជាតិ។

៣- ចូលបម្រើកងទ័ពនៃរដ្ឋបរទេសដោយស្ម័គ្រចិត្តឬបំពេញតួនាទីជាមន្ត្រីសាធារណៈនៃរដ្ឋបរទេស និងមិនព្រមលាឈប់ ទោះបីមានបញ្ជាពីរាជរដ្ឋាភិបាលកម្ពុជា។

៤- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិម ដែលពាក់ព័ន្ធនឹងការរំលោភបំពានដល់អង្គព្រះមហាក្សត្រ ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋនិងអំពើភេរវកម្ម។

ការដកសញ្ជាតិខ្មែរពីកំណើតអាចធ្វើទៅបាន លុះត្រាតែប្រជាពលរដ្ឋខ្មែររូបនោះមានអាយុ១៨(ដប់ប្រាំបី)ឆ្នាំយ៉ាងតិច និងមានសញ្ជាតិមួយផ្សេងទៀត ឬមានមូលដ្ឋានដែលអាចជឿជាក់ថា ប្រជាពលរដ្ឋខ្មែររូបនោះអាចទទួលបានសញ្ជាតិផ្សេងទៀតឬទទួលបានការគាំពារពីរដ្ឋបរទេស។

ការដកសញ្ជាតិខ្មែរពីកំណើត ត្រូវធ្វើឡើងបន្ទាប់ពីទទួលបានយោបល់ពីគណៈកម្មការជាតិផ្តល់យោបល់លើការដកសញ្ជាតិខ្មែរពីកំណើត។

### ផ្នែកទី២
### គណៈកម្មការជាតិផ្តល់យោបល់លើការដកសញ្ជាតិខ្មែរពីកំណើត

**មាត្រា៤១ .-**

ត្រូវបានបង្កើតគណៈកម្មការជាតិផ្តល់យោបល់លើការដកសញ្ជាតិខ្មែរពីកំណើត ដែលសរសេរជាអក្សរកាត់ថា«**គ.ជ.ដ.ខ.**» ជាយន្តការរបស់រាជរដ្ឋាភិបាល ក្នុងការពិនិត្យ ស្រាវជ្រាវ វាយតម្លៃ និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការដកសញ្ជាតិខ្មែរពីកំណើត ចំពោះប្រជាពលរដ្ឋខ្មែរដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា៤០នៃអនុក្រឹត្យនេះ។

**មាត្រា៤២ ._**

**គ.ជ.ដ.ខ.** មានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | | ប្រធាន |
| ២- | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ១ រូប | អនុប្រធាន |
| ៣- | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១ រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- | រដ្ឋលេខាធិការក្រសួងការពារជាតិ | ១ រូប | អនុប្រធាន |
| ៥- | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ១ រូប | អនុប្រធាន |
| ៦- | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១ រូប | សមាជិក |
| ៧- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| ៨- | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| ៩- | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១ រូប | សមាជិក |
| ១០- | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ១ រូប | សមាជិក |
| ១១- | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ១ រូប | សមាជិក |
| ១២- | អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | | សមាជិក |
| ១៣- | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | | សមាជិក |
| ១៤- | អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | | សមាជិក |
| ១៥- | អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | | សមាជិក។ |

**គ.ជ.ដ.ខ.** អាចមានសមាសភាពបន្ថែមជាតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាលតាមការចាំបាច់។ សមាសភាពបន្ថែម ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

សមាសភាពជាក់ស្ដែងនៃ**គ.ជ.ដ.ខ.** ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៤៣ ._**

**គ.ជ.ដ.ខ.** មានភារកិច្ចដូចខាងក្រោម៖

- សិក្សានិងប្រមូលចងក្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដើម្បីជាមូលដ្ឋានក្នុងការកំណត់និងវាយតម្លៃអំពីប្រភេទនៃអំពើល្មើសណាមួយរបស់ប្រជាពលរដ្ឋខ្មែរ ដែលអាចត្រូវបានដកសញ្ជាតិខ្មែរពីកំណើត
- ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដកសញ្ជាតិខ្មែរ ឱ្យបានទូលំទូលាយ
- សហការជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្រាវជ្រាវអំពីអត្តសញ្ញាណប្រជាពលរដ្ឋខ្មែរពីកំណើតដែលកំពុងរស់នៅឯបរទេសនិងស្វែងរកព័ត៌មានពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិផ្សេងទៀត ឬមានមូលដ្ឋានដែលអាចជឿជាក់ថា ប្រជាពលរដ្ឋខ្មែររូបនោះអាចទទួលបានសញ្ជាតិផ្សេងទៀតឬទទួលបានការគាំពារពីរដ្ឋបរទេស
- សហការជាមួយក្រសួងយុត្តិធម៌ ដើម្បីទទួលបាននូវសេចក្ដីសម្រេចផ្ដន្ទាទោសស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ពាក់ព័ន្ធនឹងបទល្មើសដូចមានចែងក្នុងចំណុចទី៤ មាត្រា៤០នៃអនុក្រឹត្យនេះ
- សហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ក្នុងការស្រាវជ្រាវ ស៊ើបអង្កេត និងប្រមូលភស្តុតាងពាក់ព័ន្ធសកម្មភាពប្រព្រឹត្តអំពើល្មើសណាមួយរបស់ប្រជាពលរដ្ឋខ្មែរពីកំណើត ដើម្បីជាមូលដ្ឋានគតិយុត្តក្នុងការដកសញ្ជាតិខ្មែរពីកំណើត

- ពិនិត្យ ពិភាក្សា និងវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយនិងហ្មត់ចត់បំផុតចំពោះអំពើល្មើសនិងភស្តុតាងពាក់ព័ន្ធនានាដែលប្រមូលបាន មុននឹងលើកយោបល់ជូនរាជរដ្ឋាភិបាល ដើម្បីស្នើសុំដកសញ្ជាតិខ្មែរពីកំណើត
- រៀបចំរបាយការណ៍លម្អិតអំពីកិច្ចដំណើរការនៃការស្រាវជ្រាវ ការស៊ើបអង្កេត និងការប្រមូលភស្តុតាងព្រមទាំងការពិនិត្យ ពិភាក្សា និងវាយតម្លៃទៅលើប្រជាពលរដ្ឋខ្មែរ ដែលជាកម្មវត្ថុក្នុងការលើកយោបល់ស្នើសុំដកសញ្ជាតិខ្មែរពីកំណើត
- លើកយោបល់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេចនិងលើកសំណើទូលថ្វាយព្រះមហាក្សត្រដើម្បីសម្រេចចេញព្រះរាជក្រឹត្យដកសញ្ជាតិខ្មែរពីកំណើត
- សម្របសម្រួលក្នុងការរៀបចំលិខិតឆ្លើយតបឬសេចក្ដីបំភ្លឺរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការដកសញ្ជាតិខ្មែរពីកំណើត
- រៀបចំរបាយការណ៍អំពីសកម្មភាពការងាររបស់**គ.ជ.ដ.ខ.** ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៤៤ .-**

**គ.ជ.ដ.ខ.** ត្រូវធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធាន**គ.ជ.ដ.ខ.**។

កិច្ចប្រជុំរបស់**គ.ជ.ដ.ខ.** ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធាន**គ.ជ.ដ.ខ.**។ ក្នុងករណីប្រធាន**គ.ជ.ដ.ខ.** អវត្តមានឬមានធុរៈ ប្រធាន**គ.ជ.ដ.ខ.** អាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៤៥ .-**

**គ.ជ.ដ.ខ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ សម្រាប់ដំណើរការការងារ។

**មាត្រា៤៦ .-**

**គ.ជ.ដ.ខ.** មានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ជាលេខាធិការដ្ឋាន ដើម្បីគាំទ្រដល់ដំណើរការការងារ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អាចប្រើប្រាស់មន្ត្រីជំនាញក្រោមឱវាទរបស់ខ្លួន ក្នុងការបំពេញតួនាទីជាលេខាធិការដ្ឋាន**គ.ជ.ដ.ខ.**។

**មាត្រា៤៧ .-**

លេខាធិការដ្ឋាន**គ.ជ.ដ.ខ.** មានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលកិច្ចការរដ្ឋបាលរបស់**គ.ជ.ដ.ខ.** ស្របតាមការណែនាំនិងការសម្រេចរបស់**គ.ជ.ដ.ខ.**
- រៀបចំផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដកសញ្ជាតិខ្មែរឱ្យបានទូលំទូលាយ
- ប្រមូលចងក្រងឯកសារនិងភស្តុតាងពាក់ព័ន្ធនឹងជនដែលជាកម្មវត្ថុនៃការដកសញ្ជាតិខ្មែរពីកំណើតព្រមទាំងរៀបចំរបាយការណ៍ជូន**គ.ជ.ដ.ខ.**
- រៀបចំគម្រោងចំណាយរបស់**គ.ជ.ដ.ខ.**
- សម្របសម្រួលរៀបចំកិច្ចប្រជុំរបស់**គ.ជ.ដ.ខ.**
- រៀបចំកំណត់ហេតុកិច្ចប្រជុំរបស់**គ.ជ.ដ.ខ.**

- ទទួលនិងគ្រប់គ្រងសេចក្តីចម្លងព្រះរាជក្រឹត្យស្តីពីការដកសញ្ជាតិខ្មែរពីកំណើត
- គ្រប់គ្រងព័ត៌មានបុគ្គលនិងបូកសរុបជាប្រចាំនូវទិន្នន័យប្រជាពលរដ្ឋខ្មែរដែលត្រូវបានដកសញ្ជាតិ
- សម្របសម្រួលក្នុងការរៀបចំលិខិតឆ្លើយតបឬសេចក្តីបំភ្លឺរបស់**គ.ជ.ដ.ខ.** ពាក់ព័ន្ធនឹងការដកសញ្ជាតិខ្មែរពីកំណើត
- រៀបចំរបាយការណ៍អំពីសកម្មភាពការងាររបស់លេខាធិការដ្ឋាន**គ.ជ.ដ.ខ.** ជូន**គ.ជ.ដ.ខ.** តាមការកំណត់
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធាន**គ.ជ.ដ.ខ.**។

**មាត្រា៤៨ .-**

**គ.ជ.ដ.ខ.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។

## ផ្នែកទី៣
## បែបបទនិងនីតិវិធីនៃការដកសញ្ជាតិខ្មែរពីកំណើត

**មាត្រា៤៩ .-**

ការដកសញ្ជាតិខ្មែរពីកំណើតពីប្រជាពលរដ្ឋខ្មែរដែលបានប្រព្រឹត្តអំពើល្មើស ដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៣នៃមាត្រា៤០នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមបែបបទនិងនីតិវិធី ដូចខាងក្រោម៖

១- បន្ទាប់ពីទទួលបានព័ត៌មានពាក់ព័ន្ធនឹងអំពើល្មើសដែលបានកំណត់ខាងលើ **គ.ជ.ដ.ខ.**ត្រូវធ្វើការកំណត់អត្តសញ្ញាណរបស់ប្រជាពលរដ្ឋខ្មែររូបនោះឱ្យបានច្បាស់លាស់ និងធ្វើការស្រាវជ្រាវស៊ើបអង្កេត ប្រមូលភស្តុតាងនានាពាក់ព័ន្ធនឹងអំពើល្មើស ព្រមទាំងស្វែងរកព័ត៌មានពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិមួយផ្សេងទៀត ឬមានមូលដ្ឋានដែលអាចជឿជាក់ថា ជននោះអាចទទួលបានសញ្ជាតិផ្សេងទៀតឬទទួលបានការគាំពារពីរដ្ឋបរទេស។

២- បន្ទាប់ពីបានកំណត់អត្តសញ្ញាណ និងប្រមូលភស្តុតាងដូចបានកំណត់នៅក្នុងចំណុចទី១ខាងលើនេះ **គ.ជ.ដ.ខ.**ត្រូវពិនិត្យ ពិភាក្សា និងវាយតម្លៃអំពីផលប៉ះពាល់នានាដែលជននោះបានបង្កឡើងចំពោះប្រទេសជាតិ។

៣- ផ្អែកតាមលទ្ធផលនៃការពិនិត្យ ពិភាក្សា និងវាយតម្លៃ**គ.ជ.ដ.ខ.**ត្រូវធ្វើរបាយការណ៍លម្អិត ដោយភ្ជាប់នូវយោបល់របស់ខ្លួន ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច។

**មាត្រា៥០ .-**

ការដកសញ្ជាតិខ្មែរពីកំណើតពីប្រជាពលរដ្ឋខ្មែរដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិម ដែលពាក់ព័ន្ធនឹងការរំលោភបំពានដល់អង្គព្រះមហាក្សត្រ ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ និងអំពើភេរវកម្ម ដូចមានចែងក្នុងចំណុចទី៤នៃមាត្រា៤០នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមបែបបទនិងនីតិវិធី ដូចខាងក្រោម៖

១- បន្ទាប់ពីមានសាលក្រមឬសាលដីកាស្ថាពរសម្រេចផ្តន្ទាទោសលើពលរដ្ឋខ្មែរពីកំណើត **គ.ជ.ដ.ខ.** ត្រូវធ្វើការកំណត់អត្តសញ្ញាណប្រជាពលរដ្ឋខ្មែររូបនោះឱ្យបានច្បាស់លាស់ ប្រមូល និងគ្រប់គ្រងឯកសារអត្តសញ្ញាណបុគ្គល ព្រមទាំងស្វែងរកព័ត៌មានពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិផ្សេងទៀត ឬមានមូលដ្ឋានដែលអាចជឿជាក់ថា ជននោះអាចទទួលបានសញ្ជាតិផ្សេងទៀតឬទទួលបានការគាំពារពីរដ្ឋបរទេស។

២- បន្ទាប់ពីបានកំណត់អត្តសញ្ញាណ និងប្រមូលភស្តុតាងដូចបានកំណត់នៅក្នុងចំណុចទី១ខាងលើនេះ **គ.ជ.ជ.ខ.**ត្រូវពិនិត្យ ពិភាក្សា និងវាយតម្លៃអំពីផលប៉ះពាល់នានាដែលជននោះបានបង្កឡើងចំពោះប្រទេសជាតិ។

៣- ផ្អែកតាមលទ្ធផលនៃការពិនិត្យនិងវាយតម្លៃ**គ.ជ.ជ.ខ.**ត្រូវធ្វើរបាយការណ៍លម្អិត ដោយភ្ជាប់នូវយោបល់របស់ខ្លួន ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច។

**មាត្រា៥១ .-**

ការដកសញ្ជាតិខ្មែរពីកំណើតពីប្រជាពលរដ្ឋខ្មែរ ដូចមានចែងក្នុងមាត្រា៤៩ឬមាត្រា៥០នៃអនុក្រឹត្យនេះ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីទទួលបានយោបល់ពី**គ.ជ.ជ.ខ.**។

## ជំពូកទី៧
## ការដកសញ្ជាតិខ្មែរពីពលរដ្ឋខ្មែរដែលទទួលបានសញ្ជាតិខ្មែរ ដោយការទាមទារសញ្ជាតិនិងដោយសញ្ជាតូបនីយកម្ម

### ផ្នែកទី១
### លក្ខខណ្ឌនៃការដកសញ្ជាតិខ្មែរពីពលរដ្ឋខ្មែរដែលទទួលបានសញ្ជាតិខ្មែរ ដោយការទាមទារសញ្ជាតិនិងដោយសញ្ជាតូបនីយកម្ម

**មាត្រា៥២ .-**

អនុលោមតាមបញ្ញត្តិនៃមាត្រា២៩ថ្មីនៃច្បាប់ស្តីពីសញ្ជាតិ ការដកសញ្ជាតិខ្មែរពីពលរដ្ឋខ្មែរដែលទទួលបានសញ្ជាតិខ្មែរដោយការទាមទារសញ្ជាតិនិងដោយសញ្ជាតូបនីយកម្ម អាចធ្វើទៅបានក្នុងករណីណាមួយដូចខាងក្រោម៖

១- ប្រព្រឹត្តអំពើក្បត់ជាតិឬធ្វើសកម្មភាពឃុបឃិតគ្នាជាមួយបរទេស ដែលនាំឱ្យអន្តរាយដល់ផលប្រយោជន៍ស្នូលរបស់ព្រះរាជាណាចក្រកម្ពុជា។

២- ធ្វើសកម្មភាពដែលនាំឱ្យអន្តរាយដល់អធិបតេយ្យជាតិ បូរណភាពទឹកដី និងសន្តិសុខជាតិ។

៣- ចូលបម្រើកងទ័ពនៃរដ្ឋបរទេសដោយស្ម័គ្រចិត្ត ឬបំពេញតួនាទីជាមន្ត្រីសាធារណៈនៃរដ្ឋបរទេស និងមិនព្រមលាឈប់ ទោះបីមានបញ្ជាពីរាជរដ្ឋាភិបាលកម្ពុជា។

៤- បានទទួលសញ្ជាតិខ្មែរដោយការក្លែងបន្លំឬការផ្តល់ព័ត៌មានមិនពិត។

៥- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិម ដែលពាក់ព័ន្ធនឹងការរំលោភបំពានដល់អង្គព្រះមហាក្សត្រ ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ និងអំពើភេរវកម្ម។

### ផ្នែកទី២
### បែបបទនិងនីតិវិធីនៃការដកសញ្ជាតិខ្មែរពីពលរដ្ឋខ្មែរដែលទទួលបានសញ្ជាតិខ្មែរ ដោយការទាមទារសញ្ជាតិនិងដោយសញ្ជាតូបនីយកម្ម

**មាត្រា៥៣ .-**

ការដកសញ្ជាតិខ្មែរចំពោះប្រជាពលរដ្ឋខ្មែរដែលទទួលបានសញ្ជាតិខ្មែរដោយការទាមទារសញ្ជាតិ និងដោយសញ្ជាតូបនីយកម្ម ដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៣នៃមាត្រា៥២ នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមបែបបទនិងនីតិវិធី ដូចខាងក្រោម៖

១- បន្ទាប់ពីទទួលបានព័ត៌មានពាក់ព័ន្ធនឹងអំពើល្មើសដែលបានកំណត់ខាងលើ ក្រសួងមហាផ្ទៃត្រូវធ្វើការកំណត់អត្តសញ្ញាណរបស់ប្រជាពលរដ្ឋខ្មែររូបនោះឱ្យបានច្បាស់លាស់ និងត្រូវពិនិត្យសំណុំឯកសារដែលបានដាក់ពាក្យស្នើសុំសញ្ជាតិខ្មែរដំបូង ព្រមទាំងស្រាវជ្រាវ ស៊ើបអង្កេត និងប្រមូលភស្តុតាងនានាពាក់ព័ន្ធនឹងអំពើល្មើសរបស់ជននោះ។

២- ក្រសួងមហាផ្ទៃត្រូវធ្វើការវាយតម្លៃអំពីផលប៉ះពាល់នានា ដែលជននោះបានបង្កឡើងចំពោះប្រទេសជាតិ និងធ្វើរបាយការណ៍លម្អិតដោយភ្ជាប់នូវយោបល់ជូននាយករដ្ឋមន្ត្រីពិនិត្យសម្រេច។

**មាត្រា៥៤ .-**

ការដកសញ្ជាតិខ្មែរចំពោះប្រជាពលរដ្ឋខ្មែរដែលបានទទួលសញ្ជាតិខ្មែរដោយការក្លែងបន្លំឬការផ្តល់ព័ត៌មានមិនពិត ដូចមានចែងក្នុងចំណុចទី៤នៃមាត្រា៥២នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមបែបបទនិងនីតិវិធីដូចខាងក្រោម៖

១- បន្ទាប់ពីទទួលបានព័ត៌មានពាក់ព័ន្ធនឹងអំពើល្មើសដែលបានកំណត់ខាងលើ ក្រសួងមហាផ្ទៃត្រូវធ្វើការកំណត់អត្តសញ្ញាណរបស់ប្រជាពលរដ្ឋខ្មែររូបនោះឱ្យបានច្បាស់លាស់ ប្រមូលនិងគ្រប់គ្រងសំណុំឯកសារដែលបានដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដំបូងរបស់ជននោះ ព្រមទាំងស្រាវជ្រាវ ពិនិត្យ វិភាគ វាយតម្លៃ និងវិនិច្ឆ័យទៅលើសំណុំឯកសារនិងភស្តុតាងនានាពាក់ព័ន្ធនឹងការស្នើសុំសញ្ជាតិខ្មែររបស់ជននោះ ដើម្បីកំណត់ថា ជាការក្លែងបន្លំឬការផ្តល់ព័ត៌មានមិនពិត។ ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃអាចកោះអញ្ជើញសាមីខ្លួនមកបំភ្លឺបន្ថែម។

២- ក្នុងករណីមានភស្តុតាងគ្រប់គ្រាន់ និងវាយតម្លៃបានថា ប្រជាពលរដ្ឋខ្មែររូបនោះបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងចំណុចទី៤នៃមាត្រា៥២នៃអនុក្រឹត្យនេះ ក្រសួងមហាផ្ទៃត្រូវធ្វើរបាយការណ៍លម្អិតអំពីលទ្ធផលនៃការស្រាវជ្រាវនិងវាយតម្លៃ ដោយលើកយោបល់ជូននាយករដ្ឋមន្ត្រីពិនិត្យសម្រេច។

**មាត្រា៥៥ .-**

ការដកសញ្ជាតិខ្មែរចំពោះប្រជាពលរដ្ឋខ្មែរដែលត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិម ដែលពាក់ព័ន្ធនឹងការរំលោភបំពានដល់អង្គព្រះមហាក្សត្រ ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ និងអំពើភេរវកម្ម ដូចមានចែងក្នុងចំណុចទី៥នៃមាត្រា៥២នៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាមបែបបទនិងនីតិវិធី ដូចខាងក្រោម៖

១- បន្ទាប់ពីមានសាលក្រម ឬសាលដីកាស្ថាពរសម្រេចផ្តន្ទាទោសលើប្រជាពលរដ្ឋខ្មែរ ក្រសួងមហាផ្ទៃត្រូវធ្វើការកំណត់អត្តសញ្ញាណប្រជាពលរដ្ឋខ្មែររូបនោះឱ្យបានច្បាស់លាស់ ប្រមូល និងគ្រប់គ្រងឯកសារអត្តសញ្ញាណបុគ្គលជាពលរដ្ឋខ្មែររបស់ជននោះ និងពិនិត្យសំណុំឯកសារដែលបានដាក់ពាក្យស្នើសុំសញ្ជាតិខ្មែរដំបូងរបស់ជននោះ។

២- បន្ទាប់ពីបានកំណត់អត្តសញ្ញាណ និងប្រមូលភស្តុតាងដូចបានកំណត់នៅក្នុងចំណុចទី១ ខាងលើនេះ ក្រសួងមហាផ្ទៃត្រូវពិនិត្យនិងវាយតម្លៃអំពីផលប៉ះពាល់នានាដែលជននោះបានបង្កឡើងចំពោះប្រទេសជាតិ។

៣- ផ្អែកតាមលទ្ធផលនៃការពិនិត្យនិងវាយតម្លៃ ក្រសួងមហាផ្ទៃត្រូវធ្វើរបាយការណ៍លម្អិតដោយភ្ជាប់នូវយោបល់ជូននាយករដ្ឋមន្ត្រីពិនិត្យសម្រេច។

**មាត្រា៥៦ .-**

ការដកសញ្ជាតិខ្មែរពីពលរដ្ឋខ្មែរ ដូចមានចែងក្នុងមាត្រា៥៣ ឬមាត្រា៥៤ ឬមាត្រា៥៥ នៃអនុក្រឹត្យនេះ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៥៧ .-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៥៨ .-**

អនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៧កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២២៥ អនុក្រ.បក ចុះថ្ងៃទី១ ខែ ធ្នូ ឆ្នាំ២០២៥

ស្តីពីការអនុវត្តច្បាប់ស្តីពីសញ្ជាតិ

**គម្រោងនិងវិស័យអាទិភាព ដែលអ្នកវិនិយោគអាចស្នើសុំចូលសញ្ជាតិខ្មែរបាន**

១- កសិកម្ម។

២- កសិឧស្សាហកម្ម។

៣- ឧស្សាហកម្មកែច្នៃផលិតផលកសិកម្មនិងឧស្សាហកម្មកែច្នៃចំណីអាហារដែលបម្រើទីផ្សារក្នុងស្រុក ឬការនាំចេញ។

៤- សហគ្រាសកម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុក ផលិតទំនិញជំនួសការនាំចូល និង សហគ្រាសកែច្នៃសំណល់។

៥- ឧស្សាហកម្មទេសចរណ៍និងសកម្មភាពពាក់ព័ន្ធនឹងវិស័យទេសចរណ៍។

៦- ឧស្សាហកម្មឌីជីថល។

៧- ឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់ ប្រកបដោយនវានុវត្តន៍ និងការស្រាវជ្រាវនិងអភិវឌ្ឍន៍។

៨- សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព និងការអភិវឌ្ឍបណ្តុំសហគ្រាសធុនតូចនិងមធ្យម សួនឧស្សាហកម្ម និងសួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

៩- ឧស្សាហកម្មឬកម្មន្តសាលថ្មីៗ ផ្តល់តម្លៃបន្ថែមខ្ពស់ មាននវានុវត្តន៍ និងភាពប្រកួតប្រជែងខ្ពស់។

១០- ប្រភេទឧស្សាហកម្មបម្រើឱ្យខ្សែច្រវាក់ផលិតកម្មតំបន់និងសកលលោក។

១១- វិស័យធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូចនិងមធ្យម។

១២- វិស័យលំនៅឋានមានតម្លៃសមរម្យ ឬលំនៅឋានតាមតំបន់ដែលរាជរដ្ឋាភិបាលចាត់ទុកជាអាទិភាព។